My School FACT SHEET

January 2010

# អំពី *My School*

CAMBODIAN

គេហទំព័រ *My School* ផ្តល់នូវការពណ៌នាត្រួសៗអំពីសាលារៀនអូស្ត្រាលីចំនួនស្ទើរតែ១០,០០០ ដែលអាចរកឃើញទៅតាមទីកន្លែងរបស់សាលារៀន វិស័យ ឬឈ្មោះ។ វិបសាយនេះផ្តល់នូវស្ថិតិ ហើយនិងពត៌មានជាអត្ថបទ ព្រមទាំងលទ្ធផល NAPLAN (www.naplan.edu.au) ដែលអាចយកទៅប្រៀបធៀបដោយគិតជាស្ថិតិ ជាមួយនឹងសាលារៀនដូចគ្នាឯទៀតពេញទូទាំងប្រទេសអូស្ត្រាលី។

ពត៌មាននឹងមានចុះផ្សាយនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០។

## សាលារៀននីមួយៗនឹងមានទំព័រពណ៌នាត្រួសៗ ដែលមានរួមទាំង:

- សេចក្តីរៀបរាប់ជាសង្ខេបអំពីសាលារៀន
- ចំនួនសិស្ស
- ចំនួនគ្រូបង្រៀន
- អត្រាសិស្សមកសាលារៀន
- លទ្ធផលសាលាមធ្យមសិក្សាថ្នាក់ធំ
- ទិន្នន័យកំរិតថ្នាក់រៀនអំពីប្រវត្តិរបស់សិស្ស
- សន្ទស្សន៍សាលានៃតម្លៃអនុភាពផ្នែកសង្គមអប់រំរបស់សហគមន៍ (ICSEA)
- ការតភ្ជាប់ទៅនឹងវិបសាយរបស់សាលារៀន ហើយពេលណាដែលសមស្រប ការតភ្ជាប់ទៅនឹងគណៈគ្រប់គ្រងរបស់សាលារៀន
- លទ្ធផល NAPLAN របស់សាលារៀន ប្រៀបធៀបជាមួយនឹងលទ្ធផលមធ្យមក្នុងប្រទេស ហើយដោយគិតជាស្ថិតិជាមួយនឹងលទ្ធផល មធ្យមរបស់សាលារៀនដូចគ្នាឯទៀត។

## ទំព័រឯទៀតនឹងមានបង្ហាញអំពី:

- ចំនួនភាគរយនៃសិស្សដែលបានសំរេចជោគជ័យនៅកំរិត (band) ធ្វើតេស្ត NAPLAN នីមួយៗ ប្រៀបធៀបជាមួយនឹងចំនួនភាគរយនៃសិស្សដែលនៅកំរិតដូចគ្នាក្នុងប្រទេស ហើយដោយគិតជាស្ថិតិជាមួយនឹងសាលារៀនដូចគ្នាឯទៀត។
- លទ្ធផល NAPLAN របស់សាលារៀន ហើយគិតជាស្ថិតិដោយប្រៀបធៀបជាមួយនឹងលទ្ធផលរបស់សាលារៀនដូចគ្នាឯទៀតចំនួន៦០។
- បញ្ជីមានចុះដល់ទៅ២០សាលារៀន ដែលមានទីតាំងនៅក្បែរនឹងសាលារៀនដែលបានជ្រើសរើស។

## *My School* នឹងជួយលោកអ្នកដើម្បី:

- ឲ្យអាចមានលទ្ធភាពនឹងមើលឃើញយ៉ាងសង្ខេបអំពីសាលារៀនមួយ ដោយប្រើសញ្ញាបង្ហាញដែលមិនផ្លាស់ប្តូរពេញទូទាំងប្រទេស
- ប្រៀបធៀបលទ្ធផលរបស់សាលារៀនមួយ ដោយប្រៀបធៀបជាមួយនឹងលទ្ធផលមធ្យមរបស់សាលារៀនទាំងអស់ក្នុងប្រទេសអូស្ត្រាលី ហើយដោយគិតជាស្ថិតិជាមួយនឹងសាលារៀនដូចគ្នាឯទៀតពេញទូទាំងប្រទេសអូស្ត្រាលី
- រុករកមើលសាលារៀនទាំងឡាយដែលនៅក្បែរនឹងសាលារៀនមួយដែលតាំងបង្ហាញ ជាមួយនឹង hyperlinks (តំណខ្ពស់) ទៅនឹងទំព័រពណ៌នាត្រួសៗរបស់សាលារៀននោះ
- សម្គាល់ឲ្យបានដឹង ហើយរៀនអំពីសាលារៀនទាំងឡាយដែលមានលទ្ធផលខ្ពស់។